ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ........................................................

# សុន្ទរកថាបិទ
# ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៣៨ នៃប្រតិបត្តិការធនាគារកណ្តាល
## រាជធានីភ្នំពេញ ថ្ងៃទី៨ ខែតុលា ឆ្នាំ២០១៧

**សូមគោរព៖**

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ជាទីមេត្រី!**

នាពេលនេះ ពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៣៨ នៃការបង្កើតធនាគារជាតិនៃកម្ពុជាឡើងវិញបានឈានដល់ទីបញ្ចប់ហើយ។ ជារួម ខ្ញុំមានមោទកភាពជាអនេកនិងសូមវាយតម្លៃខ្ពស់ចំពោះការចូលរួមរបស់ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ដែលបានញ៉ាំងឱ្យពិធីនេះប្រព្រឹត្តទៅកាន់តែអធិកអធម និងជោគជ័យ ជាពិសេស បានធ្វើឱ្យមន្ត្រី-បុគ្គលិករបស់ធនាគារជាតិនៃកម្ពុជា ក៏ដូចជានិស្សិត ដែលជាយុវជនជំនាន់ក្រោយ បានស្វែងយល់និងចងចាំពីប្រវត្តិដ៏វែងឆ្ងាយនៃការកកើត និងការអភិវឌ្ឍប្រព័ន្ធធនាគារនិងរូបិយវត្ថុជាតិ។ យើងអាចនិយាយបានថា ការអភិវឌ្ឍដែលយើងសម្រេចបានសព្វថ្ងៃគឺមិនមែនកើតឡើងដោយងាយស្រួលនិងឯកឯងទេ ប៉ុន្តែបានប្រសូតចេញពីការរក្សាបានសុខសន្តិភាព ស្ថិរភាពនយោបាយ និងការដាក់ចេញនូវមាគ៌ាគោលនយោបាយប្រកបដោយទស្សនៈវែងឆ្ងាយរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។



ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ទន្ទឹមនេះខ្ញុំជឿជាក់ថាក្មួយៗជាយុវជននឹងយល់ច្បាស់ពីតម្លៃនៃសន្តិភាពនិងការអភិវឌ្ឍជាតិ។ ដូចដែលថ្នាក់ដឹកនាំយើងបានលើកឡើង នៅពេលណាដែលប្រទេសយើងទទួលបានសន្តិភាពពេញលេញ សេដ្ឋកិច្ចបានទទួលការរីកចម្រើនយ៉ាងឆាប់រហ័ស។ ជាក់ស្ដែង គ្រាន់តែរយៈពេល ១៨ឆ្នាំ ប៉ុណ្ណោះ ក្រោយពីទទួលបានសន្តិភាព ១០០% កម្ពុជាបានប្រែក្លាយពីប្រទេសចំណូលទាប (ដែលគេហៅថាប្រទេសក្រីក្រ) ទៅជាប្រទេសចំណូលមធ្យម។ ខ្ញុំសង្ឃឹមថា យុវជនយើងនឹងបន្តរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចឱ្យបន្តទៅមុខតាមគន្លងនៃការអភិវឌ្ឍបច្ចុប្បន្ន ដែលនឹងផ្ដល់ឱកាសកាន់តែច្រើនដល់យុវជនជំនាន់ក្រោយ ក្នុងការទទួលបានអត្ថប្រយោជន៍ដ៏ច្រើនពីការរីកចម្រើនសេដ្ឋកិច្ចនិងសង្គម ដូចក្នុងប្រទេសអភិវឌ្ឍន៍នានា នាពេលអនាគត។

ដើម្បីបន្តរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ច ក៏ដូចជាវិស័យធនាគារឱ្យកាន់តែរឹងមាំថែមទៀត ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១៦-២០២៥ ខ្ញុំសូមផ្ដាំផ្ញើមតិមួយចំនួនដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាពិសេសយុវជនទាំងអស់ ថា ៖

១/- សន្តិភាពជាគន្លឹះនៃការអភិវឌ្ឍសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងអ្វីៗទាំងអស់។ ដូច្នេះ "យើងត្រូវរួមគ្នាដើម្បីរក្សាសន្តិភាព ហើយសន្តិភាពសម្រាប់យើងទាំងអស់គ្នា"។

២/- ធនាគារកណ្ដាលមានតួនាទីសំខាន់ក្នុងដំណើរការអភិវឌ្ឍសេដ្ឋកិច្ច ប្រៀបបាននឹងបេះដូងនៅក្នុងខ្លួនដូច្នេះដែរ។ បើបេះដូងមិនរឹងមាំ មនុស្សឬសត្វមិនអាចមានសុខភាពល្អបានទេ ហើយរូបិយវត្ថុប្រៀបដូចជាឈាម ដែលមិនអាចខ្វះបាន តិចក៏មិនល្អ ច្រើនក៏មិនល្អនៅក្នុងសេដ្ឋកិច្ច ដើម្បីធ្វើឱ្យខ្លួនប្រាណមានសកម្មភាពរស់រវើកនិងសុខភាពល្អ។ ដូច្នេះ

យើងត្រូវរួមចំណែកថែរក្សាសមិទ្ធផលដែលប្រព័ន្ធធនាគារយើងសម្រេចបានរហូតដល់បច្ចុប្បន្ន ដោយបានឆ្លងកាត់ដំណាក់កាលលំបាកៗជាច្រើន។

៣/- បន្តពង្រឹងសាមគ្គីភាពផ្ទៃក្នុង ចេះជួយគ្នា និងមានស្មារតីទទួលខុសត្រូវក្នុងការងារ ដើម្បីក្លាយជាអ្នកបន្តវេនប្រកបដោយគុណវុឌ្ឍិនិងគុណធម៌

៤/- ខិតខំបន្តដុះខាត់ចំណេះដឹង និងពង្រឹងសមត្ថភាពជំនាញជាប្រចាំ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារ សំដៅរួមចំណែកទាំងអស់គ្នាក្នុងការបន្តអភិវឌ្ឍប្រព័ន្ធធនាគារដ៏រឹងមាំនិង

៥/- សូមប្រតិបត្តិតាមឱ្យបានខ្ជាប់ខ្ជួននូវពុទ្ធឱវាទដែលបានសម្តែងថា **អប្បមាទៈ សម្បាទនៈ** មានន័យថា ចូលអ្នកបំពេញករណីកិច្ចទាំងឡាយដោយសេចក្តីមិនប្រមាថ។

ជាថ្មីម្តងទៀត តាងនាមធនាគារជាតិនៃកម្ពុជា ខ្ញុំសូមសម្តែងការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម សម្តេចអគ្គមហាពញាចក្រី ហេង សំរិន និងសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ព្រមទាំង ឥស្សរជនខ្មែរយើងទាំងអស់ ដែលបានពុះពារឧបសគ្គគ្រប់បែបយ៉ាងក្នុងការសង្គ្រោះជាតិមាតុភូមិ និងការពារសន្តិភាពនិងស្ថិរភាពនយោបាយ មកដល់បច្ចុប្បន្ន។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរចំពោះអតីតទេសាភិបាល សមាជិកក្រុមប្រឹក្សាភិបាល មន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជាគ្រប់ជាន់ថ្នាក់ ក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍នានា ដែលបានខិតខំរួមចំណែកកសាងសមិទ្ធផលក្នុងប្រព័ន្ធធនាគារនៅកម្ពុជាឱ្យមានការរីកចម្រើនប្រកបដោយភាពរឹងមាំ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណចំពោះ លោកជំទាវ ឯកឧត្តម លោក លោកស្រី នាងកញ្ញា ដែលបានអញ្ជើញចូលរួមក្នុងអង្គពិធីនេះ និងសូមជូនពរឱ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ**